ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
ក្រសួងមហាផ្ទៃ

លេខ: ០១៩ ប្រ.ក

# ប្រកាស
## ស្តីពី
## ការតែងតាំងមន្ត្រីរាជការសម្រាប់គាំទ្រការអនុវត្តចំណាយប្រតិបត្តិការអាទិភាព ក្នុងក្របខ័ណ្ឌកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ក្នុងផែនការអនុវត្តរយៈពេល០៣ឆ្នាំ (ផអ៣) សម្រាប់ថ្នាក់ក្រោមជាតិ

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញអនុក្រឹត្យលេខ១៦ អនក្រ ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ១៩៩៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកម/១២០៨/១៤២៩ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៨ ស្តីពីការបង្កើតគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ

- បានឃើញអនុក្រឹត្យលេខ២៣ អនក្រ.បក ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០០៩ ស្តីពីការបង្កើត និងការប្រព្រឹត្តទៅរបស់លេខាធិការដ្ឋាន គ.ជ.អ.ប
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥០៩/៥២១ ចុះថ្ងៃទី២០ ខែឧសភា ឆ្នាំ២០០៩ ស្តីពីការតែងតាំងប្រធាន និងអនុប្រធានលេខាធិការដ្ឋាន គ.ជ.អ.ប
- បានឃើញអនុក្រឹត្យលេខ៦៦ អនក្រ.បក ចុះថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០១០ ស្តីពីការបង្កើត និងដាក់ឱ្យអនុវត្តចំណាយប្រតិបត្តិការអាទិភាពក្នុងក្របខ័ណ្ឌសហប្រតិបត្តិការអភិវឌ្ឍ
- យោងលិខិតលេខ ៦៤សជណ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០១២ ស្តីពីការឯកភាពជាគោលការណ៍លើលទ្ធផលនៃការជ្រើសរើសមន្ត្រីរាជការចំនួន០៤ រូប

## សម្រេច

**ប្រការ ១** ត្រូវបានតែងតាំងមន្ត្រីរាជការចំនួន ០៤ រូប ឱ្យបំពេញការងារនៅក្នុងក្របខ័ណ្ឌកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ក្នុងផែនការអនុវត្តរយៈពេល០៣ឆ្នាំ (ផអ៣) នៅខេត្តព្រះវិហារ ចំនួន ០៣រូប និងខេត្តក្រចេះ ចំនួន ០១រូប ដូចមានរាយនាមខាងក្រោមៈ

**ខេត្តព្រះវិហារ**

| | | | |
|---|---|---|---|
| ១ | លោក **ហ៊ឹម កុម្ភៈ** | ប | មន្ត្រីបច្ចេកទេសហេដ្ឋារចនាសម្ព័ន្ធ |
| ២ | លោកស្រី **ទិត្យ ឡាំង** | ស | មន្ត្រីបច្ចេកទេសហេដ្ឋារចនាសម្ព័ន្ធ |
| ៣ | លោក **ឃិត សុធារ៉ា** | ប | មន្ត្រីបច្ចេកទេសហេដ្ឋារចនាសម្ព័ន្ធ |

**ខេត្តក្រចេះ**

| | | | |
|---|---|---|---|
| ១ | លោក **ទៀង ប៊ុនថេត** | ប | មន្ត្រីបច្ចេកទេសហេដ្ឋារចនាសម្ព័ន្ធ |

**ប្រការ ២** ប្រាក់ចំណាយប្រតិបត្តិការអាទិភាពសម្រាប់អនុវត្តផែនការអនុវត្តរយៈពេល០៣ឆ្នាំ (ផអ៣) សម្រាប់មន្ត្រីដែលត្រូវបានតែងតាំងក្នុងប្រការ១ ខាងលើនេះ ត្រូវអនុវត្តចាប់ពីថ្ងៃដែលមន្ត្រីទាំងនោះបានចូលបម្រើការងារជាមួយ ផអ៣ នៃខេត្តសាមី រហូតដល់ថ្ងៃដែលកម្មវិធីចំណាយប្រតិបត្តិការអាទិភាពសម្រាប់អនុវត្ត ផអ៣ ត្រូវបានបញ្ចប់ ។

**ប្រការ ៣** បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ ៤** អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន អគ្គនាយកនៃអគ្គនាយកដ្ឋានភស្តុភារ និងហិរញ្ញវត្ថុ អគ្គាធិការនៃអគ្គាធិការដ្ឋានកិច្ចការនយោបាយ និងនគរបាល ក្រុមប្រឹក្សា និងគណៈអភិបាលខេត្តសាមី ប្រធាននាយកដ្ឋានបុគ្គលិកនិងបណ្តុះបណ្តាលវិជ្ជាជីវៈនៃក្រសួងមហាផ្ទៃ និងសាមីខ្លួនដូចមានចែងក្នុងប្រការ១ខាងលើ ត្រូវអនុវត្តប្រកាសនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែ កុម្ភៈ ឆ្នាំ ២០១២

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**ស ខេង**

**កន្លែងទទួល ÷**

- *ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ*
- *ក្រសួង-ស្ថាប័នពាក់ព័ន្ធ*
- *ក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល*

  *“ ដើម្បីជូនជ្រាប ”*
- *ដូចប្រការ ៤*
- *ឯកសារ - កាលប្បវត្តិ*